ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបុគ្គលិកដើម្បីបម្រើការងារនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដល់សាធារណៈជនឱ្យបានជ្រាបថា ក្នុងក្របខណ្ឌនៃការអនុវត្តន៍គម្រោងកសាង និងអភិវឌ្ឍសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលកម្ពុជា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាចំនួន ២ រូប មកបំពេញការងារផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីជួយសម្របសម្រួល និងគាំទ្រដល់កិច្ចដំណើការនៅក្នុងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល។ បុគ្គលិកជាប់កិច្ចសន្យានឹងមានឱកាសត្រូវបានជ្រើសរើសជាមន្ត្រីក្របខណ្ឌពេញសិទ្ធិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោយពីការវាយតម្លៃសមិទ្ធផលការងារ និងបានបម្រើការងារយ៉ាងតិច ១ ឆ្នាំ។ បុគ្គលិកជាប់កិច្ចសន្យាចំនួន ២ រូបខាងលើ ដែលត្រូវជ្រើសរើស ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម÷

- មានបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងទូទៅ, រដ្ឋបាល, ច្បាប់, ភាសា, គោលនយោបាយ, បច្ចេកវិទ្យា, ធុរកិច្ច, សេដ្ឋកិច្ច, គណនេយ្យ, ហិរញ្ញវត្ថុ, ធនាគារ ឬផ្នែកផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល
- មានបទពិសោធការងារពាក់ព័ន្ធ (ជាការប្រសើរ)
- ចេះប្រើប្រាស់កម្មវិធី Microsoft Excel & Word, PowerPoint, Internet និង Email បានល្អប្រសើរ
- ចេះអាន, សរសេរ, និងទំនាក់ទំនងជាភាសាអង់គ្លេសបានល្អប្រសើរ
- ចេះទំនាក់ទំនង និងអាចធ្វើការងាជាក្រុមបានល្អ
- មានសមត្ថភាពគ្រប់គ្រង និងដោះស្រាយការងារចាំបាច់បន្ទាន់ក្នុងពេលតែមួយ ប្រកបដោយភាពច្នៃប្រឌិត និងប្រសិទ្ធភាពខ្ពស់
- មានអាកប្បកិរិយាល្អ ពុំធ្លាប់ជាប់ទោសបទឧក្រិដ្ឋ ឬមជ្ឈិម
- មានអត្តចរិតស្លូតបូត, ស្មោះត្រង់, អត់ធ្មត់, ឧស្សាហ៍ព្យាយាម និងមានទំនួលខុសត្រូវខ្ពស់ក្នុងការងារ
- យល់ព្រមទទួល និងបំពេញកាតព្វកិច្ច លក្ខខណ្ឌនានាដែលបានកំណត់ក្នុងលក្ខន្តិកៈ និងបទប្បញ្ញត្តិនានារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

និស្សិតដែលទើបបញ្ចប់ការសិក្សាបរិញ្ញាបត្រ និងជាស្ត្រី ត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យ ។ បេក្ខជនឬបេក្ខនារីទាំងអស់ដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប (CV) និង Cover Letter ព្រមទាំង ឯកសារពាក់ព័ន្ធ មកកាន់អ៊ីមែល Bunchan_Vorthika@mef.gov.kh ចាប់ពីថ្ងៃជូនដំណឹងរហូតដល់ **ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ ត្រឹមវេលាម៉ោង ១៧:០០នាទី** ។ *សម្រាប់ព័ត៌មានបន្ថែម, សូមទំនាក់ទំនងមកតាមរយៈទូរស័ព្ទលេខ ០៧៦ ៣៣៤ ៤៤៤៣* នៅរៀងរាល់ម៉ោងធ្វើការ ។

ថ្ងៃពុធ ៨ កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ២០២២

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666